ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

៣០-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/៣០៤ ស្តីពីការតែងតាំង ឯកឧត្តម **មាសកេត្ត កែមីរ៉ាន** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ៤១៣០

៣០-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/៣០៦ ស្តីពីការតម្លើងឋានៈ និងតែងតាំងមន្ត្រីរាជការ ចំនួន ០៣រូប ៤១៣១

៣០-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/៣០៧ ស្តីពីការតែងតាំង ឯកឧត្តម **កាន់ ឈឹន** ជានាយកសាលាភូមិន្ទក្រឡាបញ្ជីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានឋានៈស្មើ **អគ្គនាយក** ៤១៣២

៣០-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/៣០៨ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនវរសេនីយ៍ឯក **ជួន ឈឿន** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៤១៣៣

៣០-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/៣០៩ ស្តីពីការប្រោសព្រះរាជទានចំពោះឧកញ៉ា **ម៉ៅ រិទ្ធីថា** នូវ **គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ៤១៣៤

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

០១-៧-២០០៥ -អនុក្រឹត្យលេខ ៨៩ អនក្រ.បក ស្តីពីការកែសំរួលខ្លឹមសារនៃអនុក្រឹត្យស្តីពីការបង្កើត អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ៤១៣៥

០១-៧-២០០៥ -អនុក្រឹត្យលេខ ៥៦៦ អនក្រ.តត ស្តីពីការកែសំរួលភារកិច្ច និងប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ៤១៣៧

០១-៧-២០០៥ -អនុក្រឹត្យលេខ ៥៦៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៤១៣៩

០១-៧-២០០៥ -អនុក្រឹត្យលេខ ៥៦៨ អនក្រ.តត ស្តីពីការតែងតាំងប្រធានអគ្គនាយករបស់ធនាគារអភិវឌ្ឍន៍ជនបទ ៤១៤០

០១-៧-២០០៥ -អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤១៤២

២-សេចក្ដីសំរេច

០៣-៧-២០០៥ -សេចក្ដីសំរេចលេខ ១៦ សសរ ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៤១៤៣

០៥-៧-២០០៥ -សេចក្ដីសំរេចលេខ ១៧ សសរ ស្ដីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងចុះពិនិត្យ ស្ថានភាពជាក់ស្ដែង នៃផ្ទៃដីរបស់ក្រុមហ៊ុនវិនិយោគនីមួយៗនៅខេត្តមណ្ឌលគីរី ៤១៤៤

៣-សារាចរណែនាំ

០១-៧-២០០៥ -សារាចរណែនាំលេខ ០៥ សរណន ស្ដីពីការផ្ដល់សម្បទានដីសេដ្ឋកិច្ចសម្រាប់គំរោង វិនិយោគនៅក្នុង ក្របខ័ណ្ឌនៃការអនុវត្តន៍បទបញ្ជា លេខ ០២ បប ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្ដីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ៤១៤៦

III-ការងារបណ្ដាក្រសួង

១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

០៥-៧-២០០៥ -ប្រកាសលេខ០២៦អបស.មពស្ដីពីគំរូឯកសណ្ឋានថ្មីសំរាប់មន្ត្រីសុខាភិបាល ៤១៤៨

២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៣១-៥-២០០៥ -លិខិតលេខ ១២៥០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ផ៉ារីស ភ្លីប** ៤១៥១

០៧-៦-២០០៥ -លិខិតលេខ ១៣០៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **(ខេមបូឌា) ឡុងយាន ហ្វាយអឺ ហ្វៃ លីមីធីត ខមភេនី** ៤១៥៣

០៧-៦-២០០៥ -លិខិតលេខ ១៣០៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **(ខេមបូឌា) ហ្វ៊ូលលំ អ៊ិនធើណេសិនណល** ៤១៥៥

១៥-៦-២០០៥ -លិខិតលេខ ១៣៨៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ឃុន សឿ** ៤១៥៧

១៥-៦-២០០៥ -លិខិតលេខ ១៣៨៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហ៊ី ឈឹង** ៤១៥៩

១៥-៦-២០០៥ -លិខិតលេខ ១៣៨៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ីធី ម៉ាត** ៤១៦១

១៥-៦-២០០៥ -លិខិតលេខ ១៣៨៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ី-ឃ្រ** ៤១៦៣

១៥-៦-២០០៥ -លិខិតលេខ ១៣៩០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
កំពត វែលលី អ៊ីស្ទេត ៤១៦៥

១៦-៦-២០០៥ -លិខិតលេខ ១៣៩៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
តាន់ ថ៊ុក ហា ៤១៦៨

១៦-៦-២០០៥ -លិខិតលេខ ១៤០០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អេច ខេ អ៊ីមផត អិចផត ៤១៧០

១៦-៦-២០០៥ -លិខិតលេខ ១៤០១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
មេនហាតធេន ឌីវេឡុបមេន ខូ អិលធីឌី ៤១៧២

១៦-៦-២០០៥ -លិខិតលេខ ១៤០៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ធី.អ.អេស ត្រេឌីង ៤១៧៣

១៦-៦-២០០៥ -លិខិតលេខ ១៤០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ូ ជីង អេឡិចត្រូនិក ខមភេនី ៤១៧៥

១៧-៦-២០០៥ -លិខិតលេខ ១៤១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អ៊ីមេជស៍ ព្រិនធើរ ៤១៧៧

២១-៦-២០០៥ -លិខិតលេខ ១៤១៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ចិន្តា ប៉ូលីគ្លីនិក ខមភេនី លីមីធីត ៤១៧៩

២១-៦-២០០៥ -លិខិតលេខ ១៤១៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ខនធីណេន លីង (ខេមបូឌា) ៤១៨១

២១-៦-២០០៥ -លិខិតលេខ ១៤១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អេស៊ា អេឡិកទ្រិក ផៅវ័រ (ខេមបូឌា) ឌីវេឡុបមេន ៤១៨៣

២១-៦-២០០៥ -លិខិតលេខ ១៤២២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
លី ហួរ គាង អ៊ីមផត អិចផត ៤១៨៥

២១-៦-២០០៥ -លិខិតលេខ ១៤២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
តាដា ៤១៨៧

២១-៦-២០០៥ -លិខិតលេខ ១៤២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ជី សុន្ធា (ខេ.វី) ភីធីអ៊ី អិលធីឌី ៤១៨៩

២១-៦-២០០៥ -លិខិតលេខ ១៤២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
(ខេមបូឌា) ហ្គោលដេន អេលីហ្វីន អ៊ិនវេសមេន ៤១៩១

២១-៦-២០០៥ -លិខិតលេខ ១៤២៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហានយូ ត្រេឌីង ៤១៩៣

២១-៦-២០០៥ -លិខិតលេខ ១៤៣០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
យេក ហ៊ុង ត្រេឌីង ៤១៩៥

២១-៦-២០០៥ -លិខិតលេខ ១៤៣១ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ថាន ស៊ូ លីន ៤១៩៧

២២-៦-២០០៥ -លិខិតលេខ ១៤៣៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ីអ៊ិម គីធីឌី អិលធីឌី ៤១៩៩

២២-៦-២០០៥ -លិខិតលេខ ១៤៤២ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
វីសិន អិមវេ ៤២០១

២២-៦-២០០៥ -លិខិតលេខ ១៤៤៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហ្សុងជីន (ខេមបូឌា) អ៊ីន ៤២០៣

២៣-៦-២០០៥ -លិខិតលេខ ១៤៤៤ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ប្រូដ (ខេមបូឌា) អិលធីឌី ៤២០៥

២៣-៦-២០០៥ -លិខិតលេខ ១៤៤៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហ្វូត លីហ្សរ អ៊ីមផត អិចផត ៤២០៦

២៤-៦-២០០៥ -លិខិតលេខ ១៤៥០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
(កម្ពុជា) ដាប់ប៊ែលយូ.អិល.ថ៊ាយ អភិវឌ្ឍន៍ កសិកម្ម ខូ អិលធីឌី ៤២០៨

២៤-៦-២០០៥ -លិខិតលេខ ១៤៥៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
រ៉ាម៉ាយ៉ាណា អ៊ីនវេសមេន ៤២១០

២៤-៦-២០០៥ -លិខិតលេខ ១៤៥៤ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ភ្នំពេញ ឡុង សិន ត្រេឌីង ៤២១២

២៤-៦-២០០៥ -លិខិតលេខ ១៤៥៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ខូខេមវីថា អាយធី & ប៊ីហ្សូនេស ៤២១៤

នស/រកត/០៦០៥/៣០៤

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម **មាសកេត្ត កែមរិន** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

មាត្រា ២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល-០៥០៦.៣២៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥

លេខ ៤៦៧ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សោឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/៣០៦

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៧២ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងសមាសភាពនៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានៈ និង តែងតាំង :

១_ឯកឧត្តម សុខ សារ៉ាធ ជាទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ ។

២_ឯកឧត្តម ឆៀន ម៉ៅ ជាទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣_ឯកឧត្តមបណ្ឌិត ពេជ្រ តិរម្យ ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ៕

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥

៣រល.០៥០៦.៣២៧

ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឌិត ទាន់

3/2

ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/៣០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១២៩៧ / ៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០១០៥ / ០១៩ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **តាន់ ឈើន** ជានាយកសាលាភូមិន្ទក្រឡាបញ្ជីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

៣៤ល.០៥០៦.៣២៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ឆាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/៣០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជាតិរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនវរសេនីយ៍ឯក ជួន ធឿន អត្តលេខ ០៤៥០ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧.០៥០៦.៣២៩

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥

លេខ ៤៣៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

212

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/៣០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា ម៉ៅ រិទ្ធីថា

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ

ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចាកស.០៥០៦.៣៣០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥

B.65

លេខ: ៤៧៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

2/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសំរួលខ្លឹមសារនៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤
- យោងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩ និងលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១
- យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការជំរុញចលនាប្រលងប្រណាំងទាក់ទាញការវិនិយោគឯកជនតាមបណ្តាខេត្ត-ក្រុង
- យោងអនុក្រឹត្យលេខ ១៥ ដល់លេខ ៣៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង
- តាមស្មារតីអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥

សម្រេច

មាត្រា ១ : កែសំរួលអនុក្រឹត្យលេខ ១៥ ដល់លេខ ៣៨អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ដោយលុបចេញ នូវសមាសភាពតំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា / គណៈកម្មាធិការវិនិយោគកម្ពុជា ដែលជាអនុប្រធានអចិន្ត្រៃយ៍ ។

មាត្រា ២ : អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវចាត់តាំង អនុប្រធានអចិន្ត្រៃយ៍ និងជាប្រធានលេខាធិការដ្ឋាន ជំនួសសមាសភាព ដែលបានលុបចេញខាងលើ ។

មាត្រា ៣ : ក្រៅពីការកែសំរួលបណ្ដាចំណុចខាងលើ ខ្លឹមសារនៃអនុក្រឹត្យស្ដីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង នៅរក្សាទុកជាធរមានដដែល ។

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណា ដែលមានកន្លងមក ហើយដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ : សហប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីក្រសួងបរិស្ថាន-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋមន្ត្រីក្រសួងផែនការ-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍-រដ្ឋមន្ត្រីគ្រប់ក្រសួង-អភិបាលគ្រប់ខេត្ត/ក្រុង-គ្រប់ប្រធានស្ថាប័ន/អង្គភាពពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី សហប្រធាន "ក.អ.ក"
-ខុទ្ទកាល័យសម្ដេចក្រុមព្រះ សហប្រធាន "ក.អ.ក"
-ដូចមាត្រា ៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការសំរួលភារកិច្ច និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានសំរួលភារកិច្ចលោក **សៀត គីមលៀង** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ពីអភិបាលស្រុកកំពង់លែង ឱ្យមកបំរើការងារនៅសាលាខេត្តកំពង់ឆ្នាំង ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **មាន់ អានលី** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៣ ជាអភិបាលស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

មាត្រា ៣ : លោក **មាន់ អានលី** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៥៧៣...អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យ លេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **គិត ស្រីវង** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៥៦៨..អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងប្រធានអគ្គនាយក របស់ធនាគារអភិវឌ្ឍន៍ជនបទ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យ លេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ

-បានឃើញអនុក្រឹត្យ លេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា ១ : តែងតាំងឯកឧត្តម ស៊ុន គន្ធរ ទីប្រឹក្សារាជរដ្ឋាភិបាល ជាប្រធានអគ្គនាយក របស់ធនាគារអភិវឌ្ឍន៍ជនបទ ជាថ្មីទៀត ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ធនាគារជាតិ នៃកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-ដូចមាត្រា ២ " ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ.....៥៦៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីជាន់ខ្ពស់ចំនួន ០៩ រូប ដែលមានស្នាដៃល្អ ក្នុងការបំរើជាតិ មាតុភូមិ ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **កែ ម៉ុនខៀវ** ទីប្រឹក្សាសម្តេចហេង សំរិន អនុប្រធានទី១ រដ្ឋសភា
២-ឯកឧត្តម **ស៊ីវុឌ្ឍ សារុន** ទីប្រឹក្សាសម្តេចហេង សំរិន អនុប្រធានទី១ រដ្ឋសភា
៣-ឯកឧត្តម **ចៅខ ឈមិន** ទីប្រឹក្សាសម្តេចហេង សំរិន អនុប្រធានទី១ រដ្ឋសភា
៤-ឯកឧត្តម **យឹម លុច្ស** ទីប្រឹក្សាសម្តេចហេង សំរិន អនុប្រធានទី១ រដ្ឋសភា
៥-ឯកឧត្តម **អ៊ុំ ឆាយ** ទីប្រឹក្សាសម្តេចហេង សំរិន អនុប្រធានទី១ រដ្ឋសភា
៦-ឯកឧត្តម **សារ៉ាម ចំនួនសារិទ្ធ** ទីប្រឹក្សាសម្តេចហេង សំរិន អនុប្រធានទី១ រដ្ឋសភា
៧-ឯកឧត្តម **អ៊ុំ មណ្ណា** ទីប្រឹក្សាសម្តេចហេង សំរិន អនុប្រធានទី១ រដ្ឋសភា
៨-ឯកឧត្តម **នូ នឹម** ទីប្រឹក្សាសម្តេចហេង សំរិន អនុប្រធានទី១ រដ្ឋសភា
៩-ឯកឧត្តម **ខឹម ម៉ិន** ទីប្រឹក្សាសម្តេចហេង សំរិន អនុប្រធានទី១ រដ្ឋសភា

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧ សសរ

សេចក្ដីសំរេច
ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំ រេ ច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលមហាអនុតំបន់ទន្លេមេគង្គលើកទី២ និងទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៥ រហូតដល់សម្ដេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-*ក្រសួងព្រះបរមរាជវាំង*

-*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

-*អគ្គលេខាធិការដ្ឋានរដ្ឋសភា*

-*ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*

-*ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

-*ដូចប្រការ ២*

-*ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៧ សសរ

សេចក្ដីសម្រេច

ស្ដីពី

ការបង្កើតគណៈកម្មការចម្រុះអន្តរក្រសួងចុះពិនិត្យស្ថានភាពជាក់ស្ដែង នៃផ្ទៃដីរបស់ក្រុមហ៊ុនវិនិយោគនីមួយៗនៅខេត្តមណ្ឌលគិរី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- ពិនិត្យការចាំបាច់របស់រាជរដ្ឋាភិបាល

<u>សម្រេច</u>

<u>ប្រការ១</u> : បង្កើតគណៈកម្មការអន្តរក្រសួងដើម្បីចុះពិនិត្យសកម្មភាពជាក់ស្ដែងនៃផ្ទៃដីដែលបានផ្ដល់ជូនក្រុមហ៊ុនវិនិយោគនីមួយៗនៅខេត្តមណ្ឌលគិរី ដូចមានសមាសភាពខាងក្រោម :

១- ឯកឧត្តម **នុត សាររាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធាន

២- ឯកឧត្តម **អ៊ិត ណូទី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអនុប្រធាន

៣- ឯកឧត្តម **គុល ទីរក្ស** អគ្គាធិការរង ក្រសួងមហាផ្ទៃ ជាសមាជិក

៤- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** ទីប្រឹក្សាឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន ជាសមាជិក

៥- លោក **នុត ពុធដារ៉ា** អគ្គនាយករងរដ្ឋបាល ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង - សំណង់ ជាសមាជិក

៦- អ្នកស្រី **ង៉ូ សុខផានី** ប្រធាននាយកដ្ឋាន ក្រសួងបរិស្ថាន ជាសមាជិក

៧- លោក **យស មុនីរ៉ាត់** អនុប្រធាននាយកដ្ឋាន ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ជាសមាជិក

ប្រការ២ : គណៈកម្មការនេះមានភារកិច្ច ÷

- សហការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ដែលពាក់ព័ន្ធ ដើម្បីចុះពិនិត្យស្រាវជ្រាវស្ថានភាពជាក់ស្តែងនៃផ្ទៃដីដែលបានផ្តល់ជូនក្រុមហ៊ុននីមួយៗហើយត្រួតជាន់គ្នារវាងក្រុមហ៊ុនមួយ និងក្រុមហ៊ុនមួយទៀត ឬ ត្រួតជាន់លើដីប្រជាពលរដ្ឋ ឬ ត្រួតជាន់លើដីសម្បទានបំរុងទុក ឬ ត្រួតជាន់លើដីព្រៃជំរកសត្វនៅក្នុងខេត្តមណ្ឌលគិរី ។
- ពិនិត្យលក្ខណៈបច្ចេកទេសនៃការរុករានដី និង ការដាំដុះកូនឈើដែលត្រូវធ្វើវិនិយោគ ។
- ប្រមូលឯកសារសំខាន់ៗ និងពត៌មានពិតជាក់ស្តែង ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យសំរេច ។

ប្រការ៣ : គណៈកម្មការចំរុះអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ក្នុងករណីចាំបាច់ ។

ប្រការ៤ : សមាជិកទាំងអស់របស់គណៈកម្មការត្រូវចូលរួមប្រជុំ និង ចុះបំពេញការងារតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីតំណាងក្រសួងណាម្នាក់មានធុរៈមិនអាចបំពេញការងាររបស់ខ្លួនបាន ក្រសួងនោះត្រូវចាត់តាំងតំណាងម្នាក់ទៀតជំនួស ។

ប្រការ៥ : មធ្យោបាយធ្វើដំណើរ សំភារៈ និង ថវិកាចំណាយផ្សេងៗអាស្រ័យដោយសាមីក្រសួងជាអ្នកទទួលបន្ទុកដោះស្រាយរៀងៗខ្លួន ។

ប្រការ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួងពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុងប្រការ១មានភារកិច្ចទទួលអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រីស្តីទី

ស ខេង

ចំលងជូន :

- ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះប្រធានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

"ដើម្បីជូននិងថ្វាយជ្រាប"

- ដូចប្រការ១និងប្រការ៦

"ដើម្បីអនុវត្ត"

- ឯកសារ - កាលប្បវត្តិ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៥ សរណន

សារាចរណែនាំ

ស្តីពី

ការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់គម្រោងវិនិយោគ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍បទបញ្ជា លេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

**** + ****

ក្នុងទិសដៅពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅក្រោមក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន ខេត្ត-ក្រុង និង ឃុំ- សង្កាត់ ឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលដាក់ចេញនូវបទបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ។ ដោយពិនិត្យឃើញសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការជម្រុញលើកទឹកចិត្តការអនុវត្តន៍គម្រោងវិនិយោគនានា ពិសេសក្នុងវិស័យកសិកម្ម ដែលត្រូវការដោយខ្វះមិនបាននូវសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័នទាំងអស់ដែលមានការពាក់ព័ន្ធ ពិសេសគឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រុមប្រឹក្សា-អភិវឌ្ឍន៍កម្ពុជា និង អាជ្ញាធរខេត្ត- ក្រុង ដូចតទៅ :

ទី១- ដោយអនុវត្តតាមបទបញ្ជា លេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅក្នុងរយៈពេលរង់ចាំអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលអនុញ្ញាតឱ្យផ្តល់សម្បទានដីសេដ្ឋកិច្ច ក្នុងទំហំមិនលើស ១០.០០០ ហត ស្របតាមបទប្បញ្ញត្តិនៃច្បាប់ភូមិបាល ជូនដល់វិនិយោគិនដែលបានចំណាយទុនរបស់ខ្លួនរួចហើយ ក្នុងការស្វែងរកទីតាំងផ្ទៃដីវិនិយោគ និង ក្នុងការរៀបចំការសិក្សាអំពីសមិទ្ធិលទ្ធភាពនៃការអនុវត្តន៍គម្រោង ហើយបានដាក់ពាក្យស៊ីវិនិយោគ និង ការសិក្សាទាំងអស់នេះជូនក្រសួង ស្ថាប័នមានសមត្ថកិច្ចរបស់ រាជរដ្ឋាភិបាល ពិនិត្យ និង សម្រេច តាមនីតិវិធីជាធរមាន ។

ទី២- ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចជូនដល់វិនិយោគិនមានលក្ខណៈគ្រប់គ្រាន់ ដូចមានចែងក្នុងចំណុចទី ១ ខាងលើ ក្រសួង ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល និង វិនិយោគិនដែលមានការពាក់ព័ន្ធត្រូវគោរពដាច់ខាតតាមល័ក្ខខ័ណ្ឌបួនយ៉ាង ដូចខាងក្រោម :

(១)- ផ្ទៃដីសម្បទានដែលត្រូវប្រគល់ជូននោះ មិនត្រូវមានការប៉ះពាល់ដល់កម្មសិទ្ធិឯកជន ឬកម្មសិទ្ធិសមូហភាពរបស់ប្រជាជននៅក្នុងតំបន់នៃគម្រោងវិនិយោគនោះឡើយ ។ ដើម្បីគោលដៅនេះ ផ្ទៃដីសម្បទានដែលត្រូវប្រគល់ជូននោះ ត្រូវតែបានធ្វើការចុះបញ្ជីត្រឹមត្រូវជាមុនសិន ស្របតាមអនុក្រឹត្យ លេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី ឬ អនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។

(២)- ត្រូវមានរៀបចំផ្ទៃដីត្រៀមបម្រុងសម្រាប់ដោះស្រាយកំណើនប្រជាជន នៅក្នុងរយៈពេលវែងខាងមុខ ។

(៣)- ត្រូវមានការធានាឱ្យប្រជាជននៅក្នុងតំបន់នៃគម្រោងវិនិយោគ អាចទទួលបាននូវផលប្រយោជន៍សមរម្យពីគម្រោងវិនិយោគនេះ ដូចជា ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព និងកាលានុវត្តភាពការងារដែលផ្សារភ្ជាប់នឹងគម្រោងវិនិយោគ រាប់ទាំងសមាហរណកម្មផលិតកម្មរបស់គ្រួសារកសិករជាមួយនឹងគម្រោងវិនិយោគនេះផងដែរ ។

(៤)- នៅក្នុងកិច្ចសន្យាសម្បទាន ត្រូវមានប្រការចែងពីល័ក្ខខ័ណ្ឌនៃការបង្អាកការអនុវត្តន៍គម្រោងវិនិយោគ នៅតាមទីតាំងផ្ទៃដីណាដែលមានទំនាស់អំពីកម្មសិទ្ធិជាមួយប្រជាជន រហូតដល់មានការដោះស្រាយរួចរាល់ត្រឹមត្រូវ ស្របតាមនីតិវិធីច្បាប់ជាធរមាន ។

គ្រប់ក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តតាមស្មារតី និង ខ្លឹមសារនៃសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០២៦ អបស. ម៣

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៥

ប្រកាស
ស្តីពី
ឯកសណ្ឋានថ្មីសំរាប់មន្ត្រីសុខាភិបាល

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ០៧០៤១/១២៤ ចុះថ្ងៃទី១៥/០៧/២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/៥៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញរបាយការណ៍ប្រជុំពិភាក្សាស្តីពីឯកសណ្ឋានមន្ត្រីសុខាភិបាលលេខ ៣៥៦/០៤ អបស-មព ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤
- តាមការចាំបាច់របស់ក្រសួងសុខាភិបាល

សំរេច
****

ប្រការ១. ត្រូវបានអនុញ្ញាតអោយផ្លាស់ប្តូរឯកសណ្ឋានមន្ត្រីសុខាភិបាល ដែលកំពុងប្រតិបត្តិការក្នុងសេវាព្យាបាល និងថែទាំ ដើម្បីលើកកំពស់គុណភាពព្យាបាលថែទាំអោយមានប្រសិទ្ធិភាព និងមានតម្លាភាព ។

ប្រការ២. ឯកសណ្ឋានប្រធាន — អនុប្រធានមន្ទីរពេទ្យ — ប្រធានផ្នែក :

- អាវសដៃវែងត្រឹមជង្គង់
- កបើកដូចអាវធំ (Croisé)
- មានហោប៉ៅបញ្ឆិតពីរ
- ខាងក្រោយមានផែកនៅខាងក្រោមចំកណ្តាល
- ខោបារាំងពណ៌ស
- មួកពណ៌ស ។

ប្រភេទ៣.- ឯកសណ្ឋានវេជ្ជបណ្ឌិតគ្រូពេទ្យមធ្យម :

- អាវសដៃវែងត្រឹមជង្គង់
- កបើកតូចធម្មតា
- មានហោប៉ៅបញ្ឆិត
- ខាងក្រោយមានផែកនៅខាងក្រោមចំកណ្ដាល
- ខោបារាំងពណ៌ស
- មួកពណ៌ស ។

ប្រភេទ៤.- ឯកសណ្ឋានឱសថការី និងទន្តបណ្ឌិត ទន្តពេទ្យ :

- អាវសដៃខ្លី –កតាំង បិតឡេវចំហៀង
- មានហោប៉ៅខាងស្ដាំ
- ខ្នងអាវ ប៉ានចង្កេះ ផែកកណ្ដាល
- ខោបារាំងពណ៌ស
- មួកពណ៌ស ។

ប្រភេទ៥.- ឯកសណ្ឋានគ្រូពេទ្យនៅផ្នែកសង្គ្រោះបន្ទាន់ (ICU) :

- អាវដៃខ្លីពណ៌ផ្ទៃមេឃសិកពីលើ
- កស្រួចមានហោប៉ៅបី
- ផែកចំហៀងសងខាង
- ខោដាក់កៅស៊ូពណ៌ផ្ទៃមេឃ
- មួកពណ៌ផ្ទៃមេឃ ។

ប្រភេទ៦.- ឯកសណ្ឋានគ្រូពេទ្យនៅផ្នែកប្លុកវះកាត់ :

- អាវប្លូដៃវែង ចងចង្កេះ ពណ៌បៃតងចាស់
- អាវដៃខ្លីពណ៌បៃតងចាស់ សិកពីលើ
- កស្រួចមានហោប៉ៅបី
- ផែកចំហៀងសងខាង
- ខោដាក់កៅស៊ូ ពណ៌បៃតងចាស់
- មួកពណ៌បៃតងចាស់ ។

ប្រភេទ៧.- ឯកសណ្ឋានគិលានុបដ្ឋាក-យិកា

- អាវដៃខ្លី កស្រួច ឡេវចំហៀង ពណ៌ស
- មានហោប៉ៅបី
- សំពុងអាវត្រឹមគូថ

-នៅចុងដៃអាវ និងលើហោប៉ៅមានចំក្រណាត់ឆ្នូត ពណ៌ខៀវចាស់-ស សំរាប់គិលានុបដ្ឋាកមធ្យម និង ពណ៌បៃតង-ស សំរាប់គិលានុបដ្ឋាកបឋម

-ខោដាក់កៅស៊ូ ពណ៌ស

-មួកពណ៌ស ។

ប្រការ៨.- ឯកសណ្ឋានឆ្មបនៅផ្នែកសម្ភព :

-អាវដៃខ្លី ពណ៌ស៊ីជំពូខ្ចី កស្រួច ឡេវចំហៀង

-មានហោប៉ៅបី

-សំរុងអាវត្រឹមគូថ

-នៅចុងដៃអាវ និងលើហោប៉ៅមានចំក្រណាត់ឆ្នូត ពណ៌ស៊ីជំពូខ្ចី-ស

-ខោដាក់កៅស៊ូ ពណ៌ស៊ីជំពូខ្ចី

-មួកពណ៌ស៊ីជំពូខ្ចី ។

ប្រការ៩.- ឯកសណ្ឋានមន្ត្រី បុគ្គលិកនៅផ្នែករដ្ឋបាល សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ សកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល :

-អាវសដៃវែង កខុប

-ខោបារាំងពណ៌ខៀវ ឬ សំពត់ពណ៌ខៀវ ។

ប្រការ១០.- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន មន្ទីរសុខាភិបាលខេត្ត-ក្រុង ព្រមទាំងមន្ត្រីសុខាភិបាលទាំងអស់ មានភារៈកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

ប្រការ១១.- រាល់លិខិតបទដ្ឋាន ឬ បទបញ្ញត្តិណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ១២.- ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

វេជ្ជ. នុត-សុខុម

ចំលងជូន:

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការងារ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
-អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
-មន្ទីរសុខាភិបាលខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៤៥៦ ពណ.ឧតក

ភ្នំពេញថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប៉ារីស ក្លឹប**

PARIS CLUB Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7745/05P ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :

លោក	**ឡាង ខៀង**	ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី	**ចាន់ នី**	អភិបាល
លោក	**សាង វណ្ណា**	អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : សណ្ឋាគារប៉ារីសជាន់ទី១ ផ្លូវកម្ពុជាក្រោម សង្កាត់ មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ គ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាដឹកជញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន [illegible]

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ឱក_ម៉ឹង

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និង កីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មក្រុងភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៣០៥ ពណ.នគក

ភ្នំពេញថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥

គោលរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន **JIAOZUO ELECTRIC HOLDING FIRE EQUIPMENT LIMITED COMPANY** . ត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **(ខេមបូឌា) ឡុងយាន ហ្វាយអឺ ហ្វៃ លីមីធីត ខមផេនី**
(CAMBODIA) LONGYUAN FIRE LIMITED COMPANY.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2421/05E ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥

មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក SHI LEI " តតិយជន "

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២២ ផ្លូវលេខ ១២២ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -សេវាដូសជុលនិងតម្លើងប្រព័ន្ធអគ្គីភ័យ វិស្វកម្មអគ្គីភ័យ- វិស្វកម្មប្រព័ន្ធទឹក - ភ្លើង
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ-ពិសេស នាំចូលសំភារៈអគ្គីភ័យ ប្រព័ន្ធការពារអគ្គីភ័យ រថយន្តអគ្គីភ័យ គ្រឿងសំណង់ ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់ផ្នែកគ្រប់គ្រងវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

រដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ខ្ញឹក_ម៉ុច

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៣៦៧ ពណ.ឧតក

ភ្នំពេញថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **(ខេមបូឌា) ហ្វុលឡឺរ អ៊ិនធើណេសិនណល**

(CAMBODIA) FULLER INTERNATIONAL Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2422/05E ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :

លោក	CHAN KAI SUEN	ប្រធានក្រុមប្រឹក្សាភិបាល
លោក	ZHAO SHUISHOU	អភិបាល
លោក	XIE PINGYUAN	អភិបាល
លោក	CHUENGKUAI SAE KHANG	អភិបាល
លោក	SU ANHENG	អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១០៨ ABEoE1 មហាវិថីម៉ៅសេទុង សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូលសំភារៈបរិក្ខារសំណង់ សំភារៈបរិក្ខារអគ្គិសនី គ្រឿងតុបតែងផ្ទះ ទោចក្រយានយន្តនិងគ្រឿងបន្លាស់ ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទូរផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផែនការវិនិយោគពាណិជ្ជកម្ម

-សេវាផ្សាយ[illegible]

-បោះពុម្ព[illegible]

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម_ប្រសិទ្ធ

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
